ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦១
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌ
លេខៈ ៥៨ "ក"
ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកោះកុង

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៨:៣០នាទី ដោយមានសមាសភាពដូចតទៅ៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

-ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តកោះកុង

**ចៅក្រមប្រឹក្សា**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

**មេធាវីការពារក្តី**

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

**-ដើម្បីជំនុំជម្រះ** លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៦១ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានមានជនជាប់ចោទឈ្មោះ [redacted]ថន ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរ ធ្វើចំការ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី០១ ទីកន្លែងកំណើតភូមិ[redacted]ខេត្តកោះកុង ទីលំនៅបច្ចុប្បន្នភូមិ[redacted]ខេត្តកោះកុង ឪពុកឈ្មោះ[redacted] (ស) ម្តាយឈ្មោះ លីម (ស) ប្រពន្ធឈ្មោះ [redacted]សុបឿន (រ) មានកូន ០៣នាក់ ទោសពីមុន **ធ្លាប់ជាប់ពន្ធនាគារខេត្តកោះកុង ។(ឃុំខ្លួនថ្ងៃទី២៨-១១-២០២០)**

***ជាប់ចោទពីបទៈ*** កាប់គាស់ រុករាន និងឆ្ការឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចច្រាំងក្រឡាច ត្រង់និយាមកាលេខៈ ០៣៣៣៨១២-១២៨៩១២៤ ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៦២** ចំណុច១ និងមាត្រា **៥៦** ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ ។

**-បានឃើញ**ដីកាសន្និដ្ឋានស្ថាពរលេខៈ **៥៦ អយ/២១** ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកោះកុង ។

**-បានឃើញ**ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ **៦៤៥ អយ/២១** ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមសាលាដំបូងខេត្តកោះកុង ។

**-បានឃើញ**ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខៈ **១០០** ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកោះកុង ។



Scanned with CamScanner

## ភាពប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង **០១:០៥នាទីរសៀល** មន្ត្រីឧទ្យានុរក្សនៃស្នាក់ការល្បាតឆាយអារ៉ែង បានសហការជាមួយកងកម្លាំងរាជអាវុធហត្ថកលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានធ្វើការល្បាតនៅចំណុចច្រាំងត្រឡាច ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង ប្រទះឃើញឈ្មោះ[redacted]ថន កំពុងធ្វើសកម្មភាព **កាប់គាស់រុករានដីព្រៃ ដោយគ្មានលិខិតអញ្ញាត** ។ មន្ត្រីឧទ្យានុរក្ស បានត្រួតពិនិត្យឃើញថា **កាប់គាស់ រុករានដីព្រៃ និងឆ្ការដើម្បីយកធ្វើកម្មសិទ្ធ** មានផ្ទៃដីទំហំ **០,៩៣ហិកតា** ដែលមាននិយាមកាលេខ: **០៣៣៣៨១២-១២៨៩១២៤** ស្ថិតនៅក្នុងតំបន់អភិរក្ស នៃឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ទើបក្រុមការងារធ្វើការឃាត់ខ្លួនតែម្តង និងដកហូតវត្ថុតាងបានកាំបិតចំនួន **០១ដើម** ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]ថន បានឆ្លើយបញ្ជាក់ថា: នៅព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ[redacted] បានមកផ្ទះខ្លួន ហើយបានជួលខ្លួនឲ្យទៅកាប់ឆ្ការព្រៃក្នុងដីរបស់ឈ្មោះ**ចន្ទ**មានទីតាំងនៅចំណុចច្រាំងត្រឡាច ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង ដោយឲ្យថ្លៃឈ្នួលក្នុងមួយថ្ងៃ **៣០,០០០ (បីម៉ឺន) រៀល** ពេលនោះខ្លួនក៏យល់ព្រម ហើយឈ្មោះ **ទូច** ក៏បាននាំខ្លួនទៅបង្ហាញទីតាំងដីដែលត្រូវកាប់ឆ្ការព្រៃ ខ្លួនក៏បានចាប់ផ្តើមកាប់ឆ្ការព្រៃពេលនោះតែម្តង រហូតដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ស្រាប់តែមានសមត្ថកិច្ចទៅដល់ទីតាំងដី ហើយឃាត់ខ្លួនរូបខ្លួន ព្រមទាំងបានដកហូតវត្ថុតាងកាំបិតចំនួន **០១ដើម** ។ ខ្លួនកាប់ឆ្ការព្រៃនោះ បានផ្ទៃដី**ទទឹងប្រហែល ៦០ម៉ែត្រ** និង**បណ្តោយប្រហែល ១០០ម៉ែត្រ** ហើយការកាប់ឆ្ការនោះខ្លួនមិនទាន់ទទួលបានថ្លៃឈ្នួលទេ ចំពោះការកាប់ឆ្ការដីព្រៃនេះ គឺខ្លួនមិនបានដឹងថាខុសច្បាប់នោះទេ ព្រោះខ្លួនគ្រាន់តែស៊ីឈ្នួលគេតែប៉ុណ្ណោះ ។

-សាក្សីឈ្មោះ[redacted]ចន្ទី បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមមន្ត្រីឧទ្យានុរក្សនៃស្នាក់ការល្បាតឆាយអារ៉ែង សហការជាមួយកម្លាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានចុះប្រតិបត្តការនៅចំណុចច្រាំងត្រឡាច ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង បានប្រទះឃើញករណី កាប់ឆ្ការដីព្រៃដោយគ្មានលិខិតអនុញ្ញាត លើផ្ទៃដីទំហំ **០,៩៣ហិកតា** ត្រង់និយាមកាលេខ **០៣៣៣៨១១២-១២៨៩១២៤** គឺស្ថិតនៅក្នុងតំបន់អភិរក្សឧទ្យានជាតិជួរភ្នំក្រវាញ ដោយឃាត់ខ្លួនបានជនសង្ស័យម្នាក់ឈ្មោះ **រិន ថន** ព្រមទាំងដកហូតបានវត្ថុតាងកាំបិតចំនួន **០១ដើម** ។ ក្រោយពីធ្វើការសាកសួរឈ្មោះ[redacted]ថន បានឆ្លើយថា ខ្លួនគ្រាន់តែស៊ីឈ្នួលកាប់ព្រៃឲ្យឈ្មោះ **ចន្ទ** តាមរយៈការចង្អុលបង្ហាញរបស់ឈ្មោះ**ទូច** ដោយទទួលបានប្រាក់ឈ្នួលក្នុងមួយថ្ងៃ **៣០,០០០(បីម៉ឺន)រៀល** ។

-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានទោសថា: មានពិរុទ្ធភាព និង ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ថន ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ ***ពីបទ:*** **កាប់គាស់ រុករាន និងឆ្ការឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចច្រាំងត្រឡាច ត្រង់និយាមកាលេខ: **០៣៣៣៨១២-១២៨៩១២៤** ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៦២ ចំណុច១** និង មាត្រា **៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ** តាងនាមតំណាងអយ្យការ សូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: **៥៦ អយ/២១** ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២១ និងស្នើសុំឲ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]ថន ទៅតាមច្បាប់ ។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] ថន បានធ្វើសេចក្តីសន្និដ្ឋានថាៈ កាលពីមុនថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ពេលព្រឹកមានឈ្មោះ **ទូច** ភេទប្រុស អាយុប្រហែល៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ រស់នៅស្រុកស្រែអំបិល ខេត្តកោះកុង ឲ្យថ្លៃឈ្នួលក្នុង**០១ថ្ងៃ ៣០,០០០រៀល (បីម៉ឺនរៀល)** ដោយឈ្មោះ **ទូច** ជាអ្នកចង្អុលបង្ហាញ ទីតាំងដីរបស់ឈ្មោះ **ចន្ទ** មកឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ថន កាប់ ហើយដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ កូនក្តីខ្លួនក៏ចាប់ផ្តើមកាប់តែម្តង ។ កូនក្តីខ្លួនទៅកាប់ព្រៃឈើរបស់ឈ្មោះ **ចន្ទ** នោះតែម្នាក់ឯង ។ កូនក្តីខ្លួនបានកាប់ទទឹងប្រហែល **៦០ម៉ែត្រ** និងបណ្តោយប្រហែល **១០០ម៉ែត្រ** មានទីតាំងនៅចំណុចច្រាំងត្រឡាច ស្ថិតនៅភូមិត្រពាំងឈើត្រាវ ។ កូនក្តីខ្លួនកាប់រហូតដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ក៏ត្រូវសមត្ថកិច្ចខាងបរិស្ថានឃាត់ខ្លួនតែម្តង ចំពោះការស៊ីឈ្នួលកាប់នេះ កូនក្តីខ្លួនមិនទាន់បានប្រាក់ឈ្នួលនៅឡើយទេ ។ កូនក្តីខ្លួនឈ្មោះ [redacted] ថន ពិតជាមិនបាន**កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ដូចការចោទប្រកាន់នោះទេ ។ អង្គហេតុបានបញ្ជាក់យ៉ាងច្បាស់ហើយថាឈ្មោះ **ទូច** មករកកូនក្តីខ្លួនស៊ីឈ្នួលកាប់ព្រៃឲ្យគាត់ក្នុង**០១ថ្ងៃ** ចំនួន **៣០,០០០រៀល (បីម៉ឺនរៀល)** លើដីរបស់ឈ្មោះ **ចន្ទ** ។ កូនក្តីនាងខ្ញុំគ្រាន់តែចង់រកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ទើបសម្រេចចិត្តទៅស៊ីឈ្នួលកាប់ព្រៃឲ្យឈ្មោះ **ទូច** ។ យោងតាមច្បាប់អំពើមួយជាអំពើល្មើសច្បាប់ ឬ ជាបទល្មើសទាល់តែសគ្រប់ធាតុផ្សំ **៣** គឺធាតុច្បាប់ ឬ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ហើយចំពោះការ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ច្បាប់ពិតជាបានចែងថា ជាបទល្មើស ដោយផ្អែក តាមមាត្រា **៦២ ចំណុចទី១** នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ ប៉ុន្តែបើយើងក្រឡេកមើលទៅលើធាតុចេតនារបស់កូនក្តីខ្លួនវិញ គាត់មិនមានចេតនាកាប់ព្រៃដើម្បីយកដីមកធ្វើជាកម្មសិទ្ធិនោះទេ ចេតនារបស់គាត់គឺស៊ីឈ្នួលកាប់ព្រៃដើម្បីបានលុយ ដោយឈ្មោះ **ទូច** ប្រាប់កូនក្តីខ្លួនថា ដីនោះជាដីរបស់ឈ្មោះ **ចន្ទ** ។ កូនក្តីខ្លួនមិនមានកូនចិត្តសូម្បីតែបន្តិចក្នុងការកាប់ព្រៃយកដីធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ ហេតុនេះការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែលថា កូនក្តីខ្លួន **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ពិតជាអយុត្តិធម៌ណាស់សម្រាប់កូនក្តីខ្លួន ។ តាមពិតទៅកូនក្តីខ្លួនក៏ជាជនរងគ្រោះមួយរូបក្នុងករណីនេះ លុយក៏មិនបានហើយ ត្រូវជាប់ពន្ធនាគារទៀត ដោយដារតែមិនមានចំណេះដឹងរៀនបានតិចតួច ទើបត្រូវមនុស្សអាក្រក់បោកប្រាស់ ត្រូវបែកពីគ្រួសារប្រពន្ធ និងកូន ។ បើកូនក្តីខ្លួនដឹងថាដីដែលកូនក្តីខ្លួនកាប់ជាដីរបស់រដ្ឋពិតណា កូនក្តីខ្លួនមិនកាប់នោះទេ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] ថន សូមធ្វើការច្រានចោលនូវការចោទប្រកាន់ទាំងអស់ ព្រោះកូនក្តីខ្លួនក៏ជាជនរងគ្រោះដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] ថន បាននិយាយសំដី និងសំណូមពរចុងក្រោយបង្អស់ថាៈ ខ្លួនសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង ដើម្បីខ្លួនបានចូលរួមរស់នៅក្នុងសង្គមវិញ ព្រោះខ្លួនដឹងកំហុសហើយ ឈប់ប្រព្រឹត្តអំពើខុសឆ្គងបែបនេះទៀតហើយ ។

**- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ**

**- ក្រោយពីបានស្តាប់ចម្លើយសាក្សី**

**-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ**

**- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ**

**-ក្រោយពីបានស្តាប់សម្តី និងសំណូមពរចុងក្រោយរបស់ជនជាប់ចោទ**



Scanned with CamScanner

# សាលាដំបូងខេត្តកោះកុង

## ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថា:

-កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង **០១:០៥នាទីរសៀល** មន្ត្រីឧទ្យានុរក្ស នៃស្នងការល្បាតឆាយអារ៉ែង បានសហការជាមួយកងកម្លាំងរាជអាវុធហត្ថកលើផ្ទៃប្រទេស និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បានធ្វើការល្បាតនៅចំណុចច្រាំងត្រឡាច ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង ប្រទះឃើញឈ្មោះ[redacted] ថន កំពុងធ្វើសកម្មភាពកាប់គាស់រុករានដីព្រៃ ដោយគ្មានលិខិតអញ្ញាត ។ មន្ត្រីឧទ្យានុរក្ស បានត្រួតពិនិត្យឃើញថា **កាប់គាស់ រុករានដីព្រៃ និងឆ្ការដើម្បីយកធ្វើកម្មសិទ្ធ** មានផ្ទៃដីទំហំ ០.៩៣ហិកតា ដែលមាននិយាមកាលេខ: **០៣៣៣៨១២-១២៨៩១២៤** ស្ថិតនៅក្នុងតំបន់អភិរក្ស នៃឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ទើបក្រុមការងារធ្វើការឃាត់ខ្លួនតែម្តង និងដកហូតវត្ថុតាងបានកាំបិតចំនួន **០១ដើម** ។ ក្រោយមកសមត្ថកិច្ចបានក៏សាងសំណុំរឿងបញ្ជូនមកតុលាការ ឃុំខ្លួនរហូតដល់សព្វថ្ងៃ ។

-ជនជាប់ចោទឈ្មោះ [redacted] **ថន** បានឆ្លើយសារភាពនាពេលសវនាការថា: ខ្លួនពិតជាបានទៅកាប់ព្រៃឲ្យឈ្មោះ **ចន្ទ** មានទីតាំងនៅចំណុចច្រាំងត្រឡាច ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង តាំងពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ក៏ត្រូវបានសមត្ថកិច្ចចាប់ខ្លួនជាក់ស្តែងពិតមែន ។ ចម្លើយសារភាពនេះ មានភាពស៊ីសង្វាកគ្នានឹងរបាយកាណ៍របស់មន្ត្រីនគរបាលយុត្តិធម៌នៃមន្ទីរបរិស្ថាន និងចម្លើយសាក្សី ដែលអាចឲ្យតុលាការជឿបាន ។

-ជនជាប់ចោទឈ្មោះ [redacted] **ថន** មានស្មារតីល្អ កម្លាំងបរិបូរណ៍ ប្រព្រឹត្តបទល្មើសដោយដឹងខុសត្រូវ ប្រព្រឹត្តអំពើធ្វើឲ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋជាពិសេសប៉ះពាល់ដល់នីត្យានុភាពក្នុងសង្គម នៃព្រះរាជាណាចក្រកម្ពុជា ។

-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌, ចម្លើយសាក្សី និង កំណត់ហេតុដកហូតវត្ថុតាង មានភាពស៊ីសង្វាក់គ្នាអាចកំណត់បានថាឈ្មោះ[redacted]**ថន** ពិតជាបានប្រព្រឹត្តបទល្មើស**កាប់គាស់ រុករាន និងឆ្ការឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចច្រាំងត្រឡាច ត្រង់និយាមកាលេខ: **០៣៣៣៨១២-១២៨៩១២៤** ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៦២ ចំណុច១** និងមាត្រា **៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ** ប្រាកដមែន។

-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] **ថន** ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ ***ពីបទ:*** **កាប់គាស់ រុករាន និងឆ្ការឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅចំណុចច្រាំងត្រឡាច ត្រង់និយាមកាលេខ: **០៣៣៣៨១២-១២៨៩១២៤** ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៦២ ចំណុច១** និងមាត្រា **៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ** ។

-ជនជាប់ចោទឈ្មោះ[redacted] **ថន** ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង មានកម្រិតវប្បធម៌ទាប ប្រព្រឹត្តអំពើល្មើសខ្វះការពិចារណា ចម្លើយសារភាពស្មោះត្រង់ គប្បីតុលាការពិចារណាអំពីស្ថានសម្រាលទោស យោងតាមមាត្រា **៩៣ , ៩៤** និងមាត្រា **១០៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

## ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង
## វិនិច្ឆ័យសេចក្តី

១.**ផ្តន្ទាទោស:** ឈ្មោះ [redacted] ថន ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារចំនួន ០៥(ប្រាំ)ឆ្នាំ តែទោសនេះត្រូវអនុវត្តដាក់ក្នុងពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ **ទោសសល់ពីនេះត្រូវព្យួរទាំងអស់** *ពីបទ:* កាប់គាស់រុករាន និងឆ្ការឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចច្រាំងត្រឡាច ត្រង់និយាមកាលេខ: ០៣៣៣៨១២-១២៨៩១២៤ ស្ថិតនៅភូមិត្រពាំងឈើត្រាវ ឃុំឬស្សីជ្រុំ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦២ ចំណុច១ និងមាត្រា ៥៦ ចំណុច៤ នៃច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ ។

២.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ វិន ថន និងចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថន ។

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃអង្គារ ០៧កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កោះកុង, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner